BBI0007

មជ្ឈមណ្ឌលឯកសារកម្ពុជា

**អ៊ុម ជី , ភេទប្រុស K05311 (បាត់ខ្លួន)**

**ប្រជាជនថ្មី**

**សម្ភាសន៍ជាមួយ អ៊ុម ឡោ, អាយុ ៦០ ឆ្នាំ "ត្រូវជាប្អូនប្រុស"**

**នៅភូមិស្វាយស ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់តំបង ។**

**ថ្ងៃទី ១៣ កក្កដា ឆ្នាំ២០០៦**

**សម្ភាសន៍ដោយៈ យិន ឆាយ**

ឆាយៈ អឺចឹងជិបូនខ្ញុំសូមជំរាបជូនពូ ពួកខ្ញុំមៅពីមជ្ឈមណ្ឌលឯលសារកម្ពុជា ពួកខ្ញុំសិក្សាស្រាវជ្រាវ អំពីប្រវត្តិសាស្រ្តក្នុងរបបខ្មែរក្រហម ដើម្បីសរសេរជាសៀវភៅទុកឲ្យក្មេងៗជំនាន់ក្រោយ សិក្សារៀនសូត្រអំពីរបបណឹង ។ ហើយម្យ៉ាងដើម្បីរៀបចំឯកសារណឹងផ្តល់ឲ្យផ្នែកច្បាប់ មួយចំនួនដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមណឹងហ្មាស់ ។ ហើយខ្ញុំមៅដល់ផ្ទះពូណឹងក៏ដោយសារតែមានតែមានប្រវត្តិរូបមួយសន្លឹកណឹងដែលឈ្មោះជីនេះ គាត់ត្រូវជាម៉េចនឹងពូ ដែរ?

ឡោៈ ត្រូវជាបងបង្កើត ។

ឆាយៈ បាទ! ជិបូនខ្ញុំចង់ស្គាល់ឈ្មោះពូ...តើពូឈ្មោះអីដែរ?

ឡោៈ អ៊ុម ឡោ ។

ឆាយៈ ពូអាយុប៉ុន្មានហើយ?

ឡោៈ ៦០

ឆាយៈ ៦០ គត់ហ្អែស?

ឡោៈ បាទ!

ឆាយៈ ពូមានស្រុកកំណើតកើតជាអីនៅណាដែរ?

ឡោៈ នៅភូមិណឹង ។

ឆាយៈ ភូមិណឹងគេហៅភូមិអី?

ឡោះ	ភូមិស្វាយស ។

ឆាយ៖	ឃុំ..

ឡោះ	ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង ។

ឆាយ៖	បាទ! ចុះគ្រួសារពូឈ្មោះអី?

ឡោះ	សី អាត ។

ឆាយ៖	បាទ! គាត់អាយុប៉ុន្មានហើយ?

ឡោះ	៥៨ ។

ឆាយ៖	ពូរៀបការកាលពីឆ្នាំណាមៅ?

ឡោះ	ឆ្នាំ ៧០ គត់ ។

ឆាយ៖	បានកូនប៉ុន្មាននាក់ដែរ?

ឡោះ	កូនបាន ៤ នាក់ ។

ឆាយ៖	ស្រីប៉ុន្មាន? ប្រុសប៉ុន្មានដែរ?

ឡោះ	ស្រី ២ ប្រុស ២ ។

ឆាយ៖	ហើសព្វថ្ងៃប្រកបមុខរបបរអីដែរ?

ឡោះ	ធ្វើស្រែ ។

ឆាយ៖	ហូបគ្រប់គ្រាន់ដែរហ្អែស៎?

ឡោះ	មិនសូវគ្រប់ប៉ុន្មានទេខ្វះខាតខ្លះ ។

ឆាយ៖	ខ្ញុំចង់ជំរាបសួរពូពីឈ្មោះ ជីហ្អស៎?

ឡោះ	បាទ!

ឆាយ៖	ឈ្មោះអ៊ុម ជី?

ឡោះ	បាទ!

ឆាយ៖	ឈ្មោះអ៊ុម ជី ណឹងត្រូវជាម៉េចរបស់លោកពូដែរ?

ឡោះ	បងបង្កើត ។

ឆាយ៖	បងបង្កើតម៉ងហ្អែស៎...?

ឡោះ	បងថ្លៃឈ្មោះ ឡាប តែខ្ញុំមិនស្គាល់នាមត្រកូលគាត់ ។

ឆាយ៖	ឈ្មោះណឹងត្រូវគេចាប់ខ្លួនតាំងពីឆ្នាំណាមានដែលដឹងទេ?

ឡោះ	ចុងឆ្នាំ ៧៨ ជិតចូល ៧៩ ហើយ ។

ឆាយៈ	បាទ! ខ្ញុំចង់សួរពីប្រវត្តដើមរបស់គាត់បន្តិច កាលពីដើមមៅគាត់បានរៀនសូត្រដល់ថ្នាក់ទីប៉ុន្មានដែរ?

ឡោះ	គាត់រៀនសាលានៅក្នុងភូមិនេះ ។

ឆាយៈ	ក្នុងភូមិស្វាយសណឹង?

ឡោះ	បាទ! ថ្នាក់ប៉ាវិដែរណឹង ។

ឆាយៈ	គាត់រៀនបានប៉ុន្មានឆ្នាំ?

ឡោះ	រៀនបាន ៥ ឆ្នាំ ។

ឆាយៈ	ថ្នាក់ទី ១២,១១,១០,៩,៨ ។

ឡោះ	បាទ!

ឆាយៈ	ហើយគាត់រៀនបានថ្នាក់ទី ៨ ណឹងគាត់ឈប់ទៅ?

ឡោះ	គាត់បានប្រពន្ធ ។

ឆាយៈ	កាលណឹងយ៉ាងម៉េចបានឈប់រៀន?

ឡោះ	កាលណឹងហ្អែស៎?

ឆាយៈ	បាទ!

ឡោះ	ដូចថាឪពុកម្ដាគាត់ខ្សត់ខ្សោយពេកគាតមៅជួយធ្វើស្រែឪពុកម្ដាយ ។

ឆាយៈ	គាត់ឈប់ពីឆ្នាំណា?

ឡោះ	ឆ្នាំ ៦៩ ។

ឆាយៈ	ពេលដែលគាត់ឈប់រៀនហើយគាត់ធ្វើអីគេ?

ឡោះ	គាត់គ្មានធ្វើអីទេ... គាត់ធ្វើតែស្រែណឹង ដល់ខ្មែរក្រហមចូលឆ្នាំ ៧៥ ណឹងគេឲ្យគាត់ធ្វើមេកងធំ ។

ឆាយៈ	អ៊ើយគាត់រៀបការពីឆ្នាំណា?

ឡោះ	គាត់រៀបការពីឆ្នាំ ៦៩ ។

ឆាយៈ	រៀបការតាំងពីឆ្នាំ ៦៩អីណោះ..?

ឡោះ	បាទ! គាត់មានកូន ១ បង កើតមៅស្លាប់ៗ មួយខ្ទិនទៀតក៏ស្លាប់ដែរ ។

ឆាយៈ	ប្រពន្ធគាត់ឈ្មោះអី?

ឡោះៈ ឈ្មោះឡាំ ។

ឆាយៈ ឈ្មោះអីឡាំ?

ឡោះៈ ខ្ញុំអត់ស្គាល់ត្រកូលគាត់ទេ ។

ឆាយៈ អីចឹងពេលគាត់ការហើយគាត់រស់នៅកន្លែងណាឹងដែរឬក៏គាត់នៅអីណា?

ឡោះៈ គាត់នៅអីណឹងដែរ ។

ឆាយៈ គាត់នៅក្នុងភូមិស្វាយសណឹងហ្អែស?

ឡោះៈ បាទ! ពេលការរួចគាត់មោអីណេះ ប្រពន្ធគាត់នៅកំពង់ឆ្នាំង ។

ឆាយៈ បាទ!ស្រុកកំណើតប្រពន្ធគាត់នៅកំពង់ឆ្នាំងហ្អែស?

ឡោះៈ បាទ!

ឆាយៈ ហើយគាត់រៀបការនៅឆ្នាំ៦៨ណឹង?

ឡោះៈ ៦៩ ។

ឆាយៈ ហើយគាត់មោនេះប្រកបមុខរបរអីដែរ?

ឡោះៈ គាត់ប្រកបមុខរបរធ្វើស្រែ ។

ឆាយៈ ធ្វើស្រែរហូតដល់ឆ្នាំណា?

ឡោះៈ រហូតដល់ឆ្នាំ ៧៥ ណឹងដែលបែកបាក់គ្នា ។

ឆាយៈ គាត់បែកបាក់ទៅណាទៅ?

ឡោះៈ ទេឆ្នាំ ៧៥ មិនទាន់បែកបាក់ទេ ដល់ឆ្នាំ ៧៧ ។

ឆាយៈ ៧៧?

ឡោះៈ បាទ!

ឆាយៈ បែកគ្នាទៅណាទៅ?

ឡោះៈ បែកគ្នាគេចាប់គាត់ ។

ឆាយៈ គេចាប់ពីកន្លែងត្រង់ណាទៅពូ?

ឡោះៈ ចាប់ពីកន្លែងត្រង់ណឹងឯង ។

ឆាយៈ ពីស្វាយសណឹង?

ឡោះៈ បាទ!

ឆាយៈ កាលណឹងពីណាគេប្រធានភូមិស្វាយសណឹង?

ឡោះ អ...និយាយពីប្រធានភូមិពីសម័យ ៧៧ ហ្អាស៎...

ឆាយៈ បាទ! ពីណាគេ?

ឡោះ មានតែអាយ៉ត ។

ឆាយៈ ចុះអនុពីណាគេ.?

ឡោះ អាណឹងនារតីមៅហើយ ។

ឆាយៈ នារតីមៅឆ្នាំណា?

ឡោះ ៧៧ ។

ឆាយៈ ដើមឆ្នាំ ៧៧ឬក៏ចុងឆ្នាំ ៧៧?

ឡោះ ខុសឬត្រូវក្អួយគិតមើល...

ឆាយៈ បាទ! ព្រោះនៅតំបន់ផ្សេងៗគ្នាវាអាចមៅចុង ៧៧ ដើមឆ្នាំ ៧៨...

ឡោះ ទេខ្ញុំវានេះទៅ ...បើម៉េចៗ លោកក្អួយឯង...

ឆាយៈ បាទ! អត់អីទេលោកពូអត់អីទេ...នឹកឃើញប៉ុន្មានឆ្លើយប៉ុណ្ណឹងទៅអត់អីទេ ។

ឡោះ ពីព្រោះខ្ញុំកាលណឹងវាវង្វេងដូចមនុស្សឆ្កួតអីចឹង ។

ឆាយៈ ចុះកាលដែលពួកនារតីមៅណឹងប្រធានភូមិចាស់ៗ...

ឡោះ គេចាប់អស់...គេជម្លៀសទៅអស់ទៅ ។

ឆាយៈ គេជម្លៀសទៅណាទៅ?

ឡោះ គេទៅកាច់រទេះ ខ្វះទៅ កែងទៅ អីណឹងណា៎ ។

ឆាយៈ អូ...បែងចែកគ្រប់កន្លែងអីចឹង?

ឡោះ បែងចែកគ្រប់កន្លែង ដល់ក្រោយមៅគេយកទៅសម្លាប់ចោលអស់ទៅ ។

ឆាយៈ ដើមឆ្នាំ ៧៨ ណឹងហ្អាស៎ ពួកនារតីមៅៗក្តោងបក្ខាប់ក្នុងភូមិយើងណឹង ។

ឡោះ បាទ!

ឆាយៈ ពូស្គាល់ពីណាមៅក្តោបក្តាប់ក្នុងភូមិយើងនេះ?

ឡោះ ក្តោបក្តាប់នៅនេះមានឈ្មោះ យ៉ត...ដែលពីប្រធានភូមិចាស់មុនហ្អាស៎...

ឆាយៈ បាទ!បន្តពីប្រធានភូមិចាស់...

ឡោះ ឈ្មោះ យ៉ត ។

ឆាយៈ ហើយឈ្មោះអីទៀត?

ឡោះៈ ឈ្មោះកេង ។

ឆាយៈ កេង ហ្អែស៎? ឈ្មោះអីទៀតពូរៀបរាប់មើល...?

ឡោះៈ ខ្ញុំចេះតែភ្លេចឈ្មោះអីទេ...

ឆាយៈ បាទ! អត់អីទេ...ចុះប្រធានឃុំឈ្មោះអី?

ឡោះៈ ឈ្មោះ ផន ។

ឆាយៈ ហើយឈ្មោះអីទៀត?

ឡោះៈ ផន ណឹងហើយប្រធានឃុំ...ឃុំសម័យណឹងហ្អាស់...

ឆាយៈ បាទ!

ឡោះៈ សម័យប៉ុលពត ។

ឆាយៈ ចុះប្រធានសហករណ៍ឈ្មោះអីដែរ?

ឡោះៈ ...?

ឆាយៈ ភ្លេចហើយហ្អែស...?

ឡោះៈ ភ្លេច ។

ឆាយៈ

ចុះកាលណឹងស្រុកយើងនេះគេហៅ ស្រុកលេខប៉ុន្មាន? ស្រុកសង្កែពីដើមគេហៅ ស្រុកលេខ ប៉ុន្មាន?

ឡោះៈ អូ...លេខខ្ញុំអត់ដឹង ។

ឆាយៈ អត់ដឹងទេ..! ចុះតំបន់?

ឡោះៈ តំបន់ ៤ ។

ឆាយៈ បាទ! កាលណឹងប្រធានតំបន់ពីណាគេ?

ឡោះៈ ណឹងនិយាយពី ៧៥ ម៉ៅក្ដួយ..?

ឆាយៈ បាទ! ពី ៧៥ ម៉ៅ...ប្រធានតំបន់ឈ្មោះអីប្រធានតំបន់ ៤ ណឹង?

ឡោះៈ ...?

ឆាយៈ ឥឡូវពូរកនឹកអត់ឃើញអត់ចោះ...ខ្ញុំចង់សួរទៅបងរបស់ពូឬក៏ប្អូនរបស់ពូឈ្មោះ អ៊ុម ជី នេះ?

ឡោះៈ បង.. បងបង្កើត ។

ឆាយៈ ដែលថាគេចាប់ខ្លួនគាត់ណឹងចាប់នៅឆ្នាំណា?

ឡោះ ជិតចូល ៧៩ ។

ឆាយៈ ជិតចូល ៧៩ ហើយ?

ឡោះ បាទ!

ឆាយៈ កាលណឹងពួកនារតីចូលមៅហើយហ្អែស?

ឡោះ បាទ! ចូលមៅហើយ ។

ឆាយៈ អីចឹងចាប់ណឹងពួកនារតីអ្នកចាប់ឬក៏ខាងណា?

ឡោះ ពួកនារតី ។

ឆាយៈ អីចឹង! គេចាប់ណឹងគេចោទពីមូលហេតុអីបានគេចាប់ណឹងពូ?

ឡោះ ខ្ញុំក៏មិនសូវដឹងដែរ...ប៉ុន្តែគេថាពួកពាយ័ព្យចាប់ទាំងអស់ ។

ឆាយៈ ដឹងថាមូលហេតុអីទេ?

ឡោះ ខ្ញុំមិនសូវដឹងដែរ ។

ឆាយៈ ពេលគេមៅចាប់ណឹងគេប្រាប់ថាម៉េចដែរ?

ឡោះ ឃើញគេមៅយកខ្លួយទៅ ។

ឆាយៈ អីចឹង! អត់មានមៅប្រាប់ក្រុមគ្រួសារថាយកទៅណាទៅណីទេ?

ឡោះ គេឲ្យទៅរើផ្ទះនៅវត្តសម្តេច...រើវត្ត ។

ឆាយៈ រើវត្ត?

ឡោះ បាទ!

ឆាយៈ វត្តអីគេ... វត្តសំរេចហ្អែស៎?

ឡោះ វត្តសម្តេច ។

ឆាយៈ វត្តសម្តេចណឹងនៅឯណាទៅ?

ឡោះ លាកខ្លួយមៅ...នៅតាមផ្លូវណឹង ។

ឆាយៈ នៅឃុំតាប៉ុនណឹង?

ឡោះ បាទ! ត្រូវទេ?

ឆាយៈ បាទ! ហើយដល់គេហៅថាទៅរើផ្ទះណឹងបាត់ម៉ងទៅ?

ឡោះ បាទ!

ឆាយៈ អត់មានដំណឹងថាយកទៅណាទៅណីទេ?

ឡោៈ អត់មានទេ ។

ឆាយៈ ហើចុះកាលណឹងប្រពន្ធគាត់មានដឹងដំណឹងថាប្ដីគេយកទៅណាទៅណីដែរទេ?

ឡោៈ អត់ដឹងដែរណឹងដូចខ្ញុំថាអីចឹងឯង មិនដឹងថាយកទៅណាទៅណីព្រោះវាបាត់ខ្លួនទៅ ។

ឆាយៈ ប្រពន្ធគាត់ឈ្មោះអី?

ឡោៈ ឈ្មោះឡាំ ។

ឆាយៈ កាលណឹងកូនប៉ុន្មាននាក់?

ឡោៈ កូនតែ ១ ណឹង ។

ឆាយៈ តែ ១ ទេ?

ឡោៈ តែកូនណឹងវាស្លាប់អស់ហើយ ។

ឆាយៈ ចុះសព្វថ្ងៃប្រពន្ធគាត់ទៅនៅឯណាទៅ?

ឡោៈ ទៅនៅអូស្ត្រាលីអីណោះ ។

ឆាយៈ ទៅនៅអូស្ត្រាលី?

ឡោៈ ...?

ឆាយៈ ចុះកូន?

ឡោៈ កូនមានអីណាអស់ហើយ ។

ឆាយៈ កូនស្លាប់អស់ហើយ?

ឡោៈ បាទ!

ឆាយៈ ហើគាត់ទៅនៅអូស្ត្រលីដែលបានមកលេងស្រុកភូមិដែរទេ?

ឡោៈ គាត់មកដែរ តែមកតែកំពង់ឆ្នាំងអីណោះស្រុកកំណើតគាត់អីណោះ មិនដែលមកអីណេះ ផង ។

ឆាយៈ អូ..មកតែកំពង់ឆ្នាំងទេនែស៎?

ឡោៈ បាទ!

ឆាយៈ គាត់មានគ្រួសារថ្មីទៀតហើយឬនៅ?

ឡោៈ ទេគាត់មាន...បែបមានហើយមើលទៅ ។

ឆាយៈ ប្រពន្ធរបស់ជីណឹងមកទល់ឥឡូវអាយុប្រហែលប៉ុន្មានហើយ?

ឡោះ	អាយុប្រហែលជា ៦១ ។

ឆាយៈ	កាលមុនគាត់បានចេញទៅអូស្រ្តាលីគាត់នៅឯណា?

ឡោះ	គាត់នៅស្វាតាអន ។

ឆាយៈ	ស្វាតាអន?

ឡោះ	បាទ!

ឆាយៈ	អាណឹងនៅក្នុងឃុំអីដែរ?

ឡោះ	ឃុំព្រែកស្ដោ ។

ឆាយៈ	កាលណឹងគាត់ធ្វើម៉េចបានគាត់បានទៅ នៅអូស្រ្តាលី?

ឡោះ	សួរដល់ត្រង់ណឹងខ្ញុំមិនដឹងប្រវត្តគាត់ទេ ។

ឆាយៈ	គាត់មានបានទៅដល់ជំរុំដល់អីទេ បានៗទៅ ...?

ឡោះ	គាត់ទៅជំរុំ ។

ឆាយៈ	អីចឹង! អាណឹងវាមានដំណើររឿងវាអីចឹង.. ។

ឡោះ	បាទ!

ឆាយៈ	ដល់ទៅដល់នោះដំបូងមានបងប្អូនគេមៅធានាឬក៏អង្គការ ។

ឡោះ	អង្គការ មានបងប្អូនអីណាមៅធានាមានតែអង្គការ ។

ឆាយៈ	អីចឹងគាត់អត់មានដឹងថាប្ដីគាត់ត្រូវគេបញ្ជូនទៅណាទៅណីទេអីចឹងពីមុនមៅ?

ឡោះ	បាទ!ដល់គេយកពីគាត់មៅវាបែកបាក់ពីណឹងទៅមិនដឹងអីណាអីណី ។

ឆាយៈ	អត់មានដឹងថាគេបញ្ជូនទៅទួលស្លែងទេ ហើយពេលបែកហើយក៏អត់មាន...

ឡោះ	គាត់បែកបាក់ទៅខ្ញុំទៅយកគាត់ពីស្រុកមោងមៅ ។

ឆាយៈ	បាទ!

ឡោះ	ខ្ញុំទៅយកផ្ទាល់ដៃ ។

ឆាយៈ	អត់មានបានទៅមើលទួលស្លែងអីសង្ស័យថាប្ដីត្រូវគេចាប់ទៅណីអីទេ?

ឡោះ	អត់...បើខ្ញុំបានទៅមើល ។

ឆាយៈ	ហើយពូបានទៅមើល មានបានដើរមើលរូបថតរបស់គាត់ដែរទេ?

ឡោះ	ខ្ញុំដើរមើល បែបមើលមិនសព្វទេ ។

ឆាយៈ	កាលបែកហើយណឹងហ្អែស៎?

ឡោះ	អត់ទេ...ឆ្នាំ ២០០០នេះ ។

ឆាយៈ	បាទ! ចុះពូកាលណឹងគេជម្លៀសពូទៅណាដែរ?

ឡោះ	ខ្ញុំគ្មានទៅណាទេ ខ្ញុំនៅស្វាតាអន...អូ..គេជម្លៀសទៅដល់ភ្នំតាគ្រៀមអីណោះ ។

ឆាយៈ	នៅស្រុកអីអាណឹង?

ឡោះ	ភ្នំតាគ្រៀមស្រុកសង្កែដែរ ។

ឆាយៈ	ស្រុកសង្កែ...?

ឡោះ	ទេមិនមែនស្រុកសង្កែទេ ស្រុកបាត់តំបង ។

ឆាយៈ	បាទ! ហើទៅដល់ណឹងគេឲ្យធ្វើអីគេ?

ឡោះ	គេឲ្យកិនស្រូវ ។

ឆាយៈ	នៅមាស៊ីនស្រូវណឹងម៉ង?

ឡោះ	បាទ! គេឲ្យកិនស្រូវ ។

ឆាយៈ	ហើយគេឲ្យកិនណឹងដាក់ដែនការយ៉ាងម៉េចដែរ?

ឡោះ	គេឲ្យកិនណឹងមួយថ្ងៃឲ្យបាន ៣ ការ៉ុងឲ្យគេ ៣ បាវឲ្យគេ ។

ឆាយៈ	៣ បាវ អាបាវឆ្នូតយើងណឹងហ្អែស៎?

ឡោះ	បាទ!

ឆាយៈ	ហើយកិនបានដែរអត់?

ឡោះ	មិនបានគេសំលេះចោល ។

ឆាយៈ	ហើបានដែរអត់អីចឹង?

ឡោះ	បាន ។

ឆាយៈ	អ៊ើ...៣ បាវឆ្នូតណឹងយើងកិនតែម្នាក់ឯងឬក៏កិន ២ នាក់?

ឡោះ	២ នាក់ ។

ឆាយៈ	ហើចេះតែធ្វើម៉ាថ្ងៃវាស់ល្ងាចអីចឹងទៅឬក៏មានពេលសំរាកដែរ?

ឡោះ	សំរាកពេលបបរ ។

ឆាយៈ	រួចបបរហើយធ្វើទៀតទៅ?

ឡោះ	ធ្វើទៀត អត់មានបានសំរាកទេ ។

ឆាយៈ	អូ..នៅកិនស្រូវណឹងគេឲ្យហូបបបរដែរ?

ឡោះ	ហូបបបរ តែបបរគេគ្រាន់ជាងប្រជាជន ។

ឆាយៈ	ហូបឆ្អែតទេ?

ឡោះ	បាទ! បបរខាប់ ។

ឆាយៈ ហើចុះម្ហូបអីយ៉ាងម៉េចដែរ?

ឡោៈ ម្ហូបធម្មតាទៅ ត្រូវអំបិលៗទៅ ។

ឆាយៈ អត់មានត្រីអត់មានសាច់អីទេ?

ឡោៈ ជួនមានត្រីទៅ ជួនមានសាច់គោទៅ ។

ឆាយៈ អាណឹងកាលពីឆ្នាំណា...ឆ្នាំ ៧៥ ណឹង?

ឡោៈ ឆ្នាំ ៧៥ ណឹងហើយ ។

ឆាយៈ អីចឹង..ចុះធ្វើអាណឹងបានប៉ុន្មានឆ្នាំទៅ ?

ឡោៈ ខែ ១ ឆ្នាំ ៧៥ ។

ឆាយៈ អូ..ធ្វើណឹងធ្វើតែ១ឆ្នាំទេហ្អែស៎?

ឡោៈ បាទ!

ឆាយៈ អាណឹងទៅណឹងគេមានកងមានក្រុមគេដូចថាអ្នកធ្វើអង្ករអ្នកកិនស្រូវ?

ឡោៈ បាទមាន ។

ឆាយៈ ប្រធានក្រុមគេពីណាគេកាលណឹង?

ឡោៈ ...ប៉ុន្តែប្រធានកងណឹងគេវ៉ៃចោល... ឈ្មោះ ចាន់ណឹងគេវ៉ៃចោល ។

ឆាយៈ ឈ្មោះ ចាន់ ។

ឡោៈ បាទ! គេវ៉ៃចោលនៅផ្សារដើមដូង ។

ឆាយៈ មូលហេតុអីបានគេវ៉ៃចោល?

ឡោៈ ថាបិទបន្ទប់ដុតប្រពន្ធកូនដុតឪពុកម្ដាយគេ ។

ឆាយៈ អ្ហ៎...ហើមែនដែរអត់ទេ?

ឡោៈ មែន...ពិត ។

ឆាយៈ ហើហេតុអីបានគាត់ណឹងដុកឪពុកហើកូនគេចោល?

ឡោៈ គេថាខ្មាំង ។

ឆាយៈ ហើដុតណឹងស្លាប់ប៉ុន្មាននាក់?

ឡោៈ ម៉ាគ្រួសារម៉ង ។

ឆាយៈ ម៉ាគ្រួសារប៉ន្មាននាក់ទៅ?

ឡោៈ ខ្ញុំឃើញគេវ៉ៃស្លាប់នៅផ្សារដើមដូង ។

ឆាយៈ ងាប់អាមេកងណឹងហ្អែស៎?

ឡោះ បាទ!

ឆាយៈ មេកងណឹងគាត់សម្លាប់គេហើយគេចាប់គាត់ទៅ?

ឡោះ បាទ! ដល់យួនរំដោះបានម៉ោវាម៉ោដែរ ។

ឆាយៈ ម៉ោដែរពីណាអ្នកសម្លាប់?

ឡោះ ប្រជាជនគេវ៉ៃគ្នា ។

ឆាយៈ វ៉ៃណឹងពួកគ្នាម៉ងហ្អែស៎?

ឡោះ ឈ្មោះ ចាន់ ។

ឆាយៈ អូ..មេកងណឹងឈ្មោះ ចាន់.

ឡោះ បាទ!

ឆាយៈ គាត់ណឹងកាចហ្អែស៎?

ឡោះ កាចបាគេធ្វើបាប..ដុតម៉ាគ្រួសារទាំងឪពុកទាំងម្ដាយទាំងកូនតូចៗងាប់តែទាំងអស់ ។

ឆាយៈ បាទ! ដល់អីចឹងគេយកអាមេកងឈ្មោះ ចាន់ណឹងទៅវ៉ៃចោលដែរទៅ?

ឡោះ វ៉ៃចោលហើយគេកាត់ក..អាណឹងខ្ញុំឃើញ នឹងភ្នែកហើយ ។

ឆាយៈ បាទ!

ឡោះ លោកក្មួយក្រែងលោខ្ញុំរអាក់រអួលអីសុំទោសណាស់...

ឆាយៈ អ៊ើយ..និយាយតាមដំណើរចុះអត់អីទេ ។ ហឺចុះពេលគេឲ្យធ្វើអង្ករធ្វើអីហើយក្រោយម៉ោ
គេឲ្យពូធ្វើអីគេ?

ឡោះ គេឲ្យធ្វើអង្ករបើមិនបានអង្ករឲ្យគេគេយកទោស បើមិនបាន ៣ បាវឲ្យគេគេយកទោស ។

ឆាយៈ ប៉ុន្តែក្នុងចំណោមណឹងមិនដែលថាមានអ្នកមួយធ្វើមិនទាន់ទេនែស៎?

ឡោះ បាទ!

ឆាយៈ ចុះក្រោយពីធ្វើអង្ករហើយគេឲ្យធ្វើអីទៀតឆ្នាំបន្ទាប់ម៉ោ?

ឡោះ ដល់រួចពីណឹងម៉ោច្រូតស្រូវឲ្យរួចមុនថ្ងៃទី ១៧ ។

ឆាយៈ ថ្ងៃទី ១៧មុនបែកហ្អែស៎?

ឡោះ គេឲ្យធ្វើឲ្យរួច បើមិនរួចទេយកទៅសម្លាប់ចោល ។

ឆាយៈ កាលណឹងនៅក្នុងភូមិស្វាយសណឹងដដែលហ្អែស៎?

ឡោះ	បាទ!

ឆាយៈ	កាលណឹងប្រជាជនថ្មីដែលជម្លៀសមៅពីគ្រប់កន្លែងណឹងមៅនៅកន្លែងណឹងដែរ?

ឡោះ	បាទ! កន្លែងនេះប្រជាជនចាស់ ។

ឆាយៈ	ហើគេឲ្យធ្វើពលកម្មអីហូបចុកអីយ៉ាងម៉េច?

ឡោះ	គេឲ្យហូបបបរ ។

ឆាយៈ	ហូបបបរដូចគ្នាទាំងអស់អីចឹងទៅ?

ឡោះ	អាខាងណោះខ្ញុំអត់ដឹងទេ អាខាណោះគេឲ្យហូបបបរ ។

ឆាយៈ	គេវាល់ចែកអីចឹងដែរ?

ឡោះ	១កាគេណឹង ។

ឆាយ	កា របស់អាមេរិកកាំងណឹងហ្មែស៎?

ឡោ	បា! ១ នាក់ ១កាណឹង ។

ឆាយ	ហើបបរណឹងគោកឬក៏រាវ ។

ឡោ	បបររាវហ្មាស៎ បបរដូចអ្នកឈឺអីចឹងហ្មាស៎ ។

ឆាយ	បាទ!ប៉ុន្តែធ្វើការទៅតាមកងតាមក្រុមរបស់គេអីចឹងទៅ.?

ឡោ	បាទ! ម្ទោះហើយវាល្វើយល្វតល្វន់ ខ្ញុំវាបាក់កាលណឹងឯង ។

ឆាយ	ហើគេដាក់ផែនការតឹងរឹងដែរទេ?

ឡោ	តឹងរឹង..ភ្ជួរស្រែបើភ្ជួរមុតដើងគោខ្លាំង ស្ទីក៏ខ្លាំងទាំងអស់ ។

ឆាយ	ចុះពេលដែលពួកនារតីដែលមៅនៅក្នុងភូមិយើងណឹងគេឲ្យយើងធ្វើពលកម្មយ៉ាងម៉េចដែរ ឲ្យលត់ដំខ្លាំងជាងអ្នកមុនឬក៏ធូជាងអ្នកមុន?

ឡោ	មៅដល់ដំបូងល្អណាស់ រំលងបានប្រហែល ១ខែ គេចាប់អាពួកពាយ័ព្យ ។

ឆាយ	គេចាប់យ៉ាងម៉េចពូនិយាយមើល?

ឡោ	ខ្ញុំក៏មិនសូវដឹងដែរ គេចាប់បណ្តោះៗម្តងមួយៗ ។

ឆាយ	តាំងពីភូមិរហូតដល់ថ្នាក់បន្តបន្ទាប់អីចឹងទៅ?

ឡោ	បាទ! មេកងអីណឹង ។

ឆាយ	ហើគេចាប់ណឹងគេច្រើនតែយកទៅណា?

ឡោ	យកទៅលើណឹងឯង ។

ឆាយ	ចុះនៅនេះអាមន្ទីរសន្តិសុខគេត្រង់ណាពូ?

ឡោ	មន្ទីរសន្តិសុខកោះស្វាយស ។

ឆាយ	អីចឹងអ្នកដែលគេចោទថាជាខ្មាំង ហើយគេឲ្យទៅរៀនសូត្រណឹងគេច្រើនបញ្ជូនទៅណឹងអីចឹង?

ឡោ	បាទ! បញ្ជូនទៅណឹង ហើយបញ្ជូនទៅវត្តក្រឡាញ់ កន្លែងគេធ្វើឃាដណឹងណា៎ ។

ឆាយ	បាទ! កាលណឹងពួកនារតីម៉ៅមានធ្វើបាបប្រជាជនយើងក្នុងស្រុកក្នុងភូមិដែរអត់?

ឡោ	មើលប្រពន្ធខ្ញុំឡើងទរុណទរា ។

ឆាយ	គេធ្វើយ៉ាងម៉េបានដល់ថ្នាក់ណឹង?

ឡោ	យើងមិនបានបញ្ចេញពលកម្មទៅ គេវ៉ៃក្រឆក់ក្រឆែងទៅ ។

ឆាយ	អូ..គេវ៉ៃគាត់ដែរ?

ឡោ	បាទ! មើលប្រពន្ធខ្ញុំនៅទរុណទរាដល់សព្វថ្ងៃ ។

ឆាយ	អុីយកាលណឹងគាត់សរសៃខ្វីឬក៏យ៉ាងម៉េច?

ឡោ	សរសៃខ្វី នៅកូនតូច ។

ឆាយ	កូនប៉ុន្មានខែ?

ឡោ	កូន ២ ខែកន្លះ កូនណឹងស្លាប់ ។

ឆាយ	បាទ! អូ..គាត់រញេរញ៉័រអីចឹងដោយសារតែគេធ្វើបាបកាលពីសម័យណឹងអីចឹងហ្អែស៎?

ឡោ	បាទ!

ឆាយ	មិនមែនដោយសារជម្ងឺឬក៏រោគរបស់គាត់ទេហ្អែស៎?

ឡោ	បាទ! ចុះទឹកចុះអីណឹងគេប្រើទៅ បើជម្ងឺរបស់គាត់ណឹងវាស្លាប់បាត់ហើយ ។

ឆាយ	បាទ! ហឺចុះចំពោះអ្នកផ្សេងទៀតពូមានដែលឃើញអំពើទារុណកម្មទៅលើអ្នកផ្សេងដែរទេ?

ឡោ	ធ្លាប់ឃើញ បន្តែខ្ញុំមិនសូវចាំទេ ឃើញចងព្យួរយោលអីចេះទៅ ហើយវ៉ៃ នឹងពូថៅទៀត ។

ឆាយ	នៅកន្លែងណាពូ?

ឡោ	នៅកន្លែងចាក់អង្កុរ ។

ឆាយ	ចាក់អង្កុរ...អាណឹងក្នុងឃុំអីដែរ?

ឡោ	ឃុំតាប៉ុននេះ ។

ឆាយ	អាណឹងសុទ្ធតែពួកនារតីទេដែលធ្វើណឹងហ្អែស៎?

ឡោ	បាទ! ពួកនារតី ។

ឆាយ	ពេលពួកនារតីមៅដូចថាអាអំពើទារុណកម្មមៅលើអ្នកស្រុកយើងណឹងខ្លាំងម៉ងហ្អែស៎?

ឡោ	ពួកនារតីណឹងវាបញ្ជាឲ្យពួកពាយ័ព្យយើងដែរ ។

ឆាយ	កាលណឹងពួកដែលមៅកាន់កាប់អាមន្ទីរសន្តិសុខអីណឹងពូមានដែលស្គាល់ដែរទេ?

ឡោ	មានស្គាល់ខ្លះប៉ុន្តែងាប់ ។

ឆាយ	ពីណាគេអ្នកងាប់ណឹង?

ឡោ

អាអ្នកងាបលណឹងចាប់ខ្ញុំយកទៅដាក់ច្រវ៉ាក់ងាប់ហើយរន្ទះបាញ់ងាប់ហើយមិនបាច់និយាយ អីទេក្មួយ ។

ឆាយ	ឲ្យតែថាស្គាល់ពីណាគេ?

ឡោ	ឈ្មោះ ឌិ ។

ឆាយ	ឈ្មោះឌិ តែមួយណឹងទេហ្អែស៎? ពីនាទៀត?

ឡោ	ងាប់អស់ហើយអាធ្វើបាបខ្ញុំ... ខ្ញុំនៅស្នាមជើង ។

ឆាយ	អូពូធ្លាប់គេចាប់យកទៅដាក់នៅមន្ទីរសន្តិសុខណឹងដែរ?

ឡោ	បាទ! ជាប់ច្រវ៉ាក់នេះស្នាមជើង ។

ឆាយ	គេយកទៅដាក់ប៉ុន្មានខែដែរ?

ឡោ	បាន ១ ខែ... ១ព្រឹក ១០០អំរែក បើមិនបានគេវ៉ៃចោល ។

ឆាយ	រែកទឹកធ្វើអីពូ.?

ឡោ	រែកទឹកដាក់ដំណាំ ។

ឆាយ	អូ..គេដាំបន្លែហ្អែស៎?

ឡោ	ដាំបន្លែល្ពៅ ត្រឡាច ។

ឆាយ	អ៊ើយដូចថាអ្នកទោសដែលនៅក្នុងមន្ទីរសន្តិសុខណឹងសុទ្ធតែគេលត់ដំពលកម្មខ្លាំងៗអីចឹង ម៉ង?

ឡោ	បាទ! ឈ្មោះ ហល ។

ឆាយ	អ្នកពាយ័ព្យណឹងដែរ?

ឡោ	បាទ! តែនៅក្រោមនារតី ។

ឆាយ	គាត់ធ្វើជាប្រធានសន្តិសុខណឹង?

ឡោ	បាទ!

ឆាយ	ប្រធានសន្តិសុខពីណាគេ?

ឡោ	ឈ្មោះ ផន ។

ឆាយ	ផន?

ឡោ	បាទ! ខាងសហករណ៍ ។

ឆាយ	ផន ណឹងប្រធានសហករណ៍ផង ហើយគ្រប់គ្រងខាសន្តិសុខផង?

ឡោ	បាទ! បន្ទាប់មៅឈ្មោះ យ៉ន ។

ឆាយ	បាទ!

ឡោ	ខ្ញុំស្នាមពីអាពតមៅនេះ ។

ឆាយ	ណឹង..ស្នាមគេដាក់ច្រវ៉ាក់ហ្អែស?

ឡោ	បាទ!

ឆាយ	អូ..គេដាក់ចោះធ្លាយជើងអីចឹង?

ឡោ	អត់ទេដាក់ទៅវាអាលាកជើង ។

ឆាយ	អូ..! ចុះអ្នកណាជាប់ជាមួយពូខ្លះកាលណឹង?

ឡោ	ឈ្មោះ គុច គាត់ចាស់វង្វេងហើយសួរក៏មិនដឹងដែរ ។

ឆាយ	បាទ! ហីពីណាទៀតក្នុងភូមិយើងណឹង?

ឡោ	ច្រើនណាស់ ។

ឆាយ	ដល់រយនាក់ទេ?

ឡោ	មិនដារយមិនដឹងជាពាន់ ។

ឆាយ	ច្រើនលើសរយទៀតហ្អែស?

ឡោ	បាទ! នៅរស់មួយៗណឹងសំណាងហើយ ។

ឆាយ	កាលសម័យណឹក្រុមគ្រួសាររបស់លោកពូមានបាត់បង់អស់ប៉ុន្មាននាក់ដែរ?

ឡោ	បាត់បង់អស់បង ១ ។

ឆាយ ឈ្មោះ ជី ណើង?

ឡោ បាទ!

ឆាយ ហើយពីណាទៀត?

ឡោ ផុតពីណើងនៅរស់ ហើយអាស្លាប់នៅសង្គមនេះស្លាប់ដោយជម្ងឺអីមិនបាច់និយាយទេណាស់ ។

ឆាយ បាទ! អីចឹងសម័យណើងពូអត់បានជម្លៀសទៅណាទេនែស់?

ឡោ ទេដូចខ្ញុំនិយាយប្រាប់លោកក្មួយអីចឹងថាជម្លៀសទៅតាគ្រៀមអីណើងណា៎ ។

ឆាយ ហីពូបានឆ្លងកាត់របបណើងអីចឹងមានបាននិយាយប្រាប់រឿងរ៉ាវក្នុងរបបណើងឲ្យកូនៗចៅៗអីឲ្យបានដឹងដែរទេ?

ឡោ ខ្ញុំនិយាយប្រាប់ ។

ឆាយ ហីវាជឿទេ?

ឡោ វាអត់ជឿខ្ញុំ វាថាអាណារបបស៊ីបបរទេ វាអត់ដឹងបើអាបងនោះដឹង ។

ឆាយ បាទ! ហីពូយល់ថារបបណើងយ៉ាងម៉េចដែរ? វាល្អចំពោះយើងឬអាក្រក់?

ឡោ ខ្ញុំអត់យល់ទេរបបណើង របបរហេមរហាមអីចឹង ។

ឆាយ ពូសព្វថ្ងៃដែលឮពត៌មានស្ដីពីការរៀបចំតុលាការកាត់ទោសមេដឹងនាំខ្មែរក្រហមដែរទេ?

ឡោ មានខ្ញុំបើកទូរទស្សន៍មើល ។

ឆាយ គេនិយាយថាម៉េចខ្លះពូ?

ឡោ គេនិយាយថាកាត់ទោសតាម៉ុកអីណើង ។

ឆាយ ហីពីណាទៀត? មានស្គាល់ទេមេដឹកនាំសម័យខ្មែរក្រហមពូស្គាល់ពីណាខ្លះ?

ឡោ ស្គាល់ដូចជាតា...

ឆាយ តាអី?

ឡោ តាម៉ុក តែមិនដែលឃើញមុខ ។

ឆាយ ពីណាទៀត?

ឡោ ប៉ុលពត ។

ឆាយ ស្លាប់ហើយ..! ហីពីណាទៀត? អៀង សារី អីដែលស្គាល់ទេ?

ឡោ ខៀវ សំផន, អៀង សារី ។

ឆាយ ហើយស្គាល់ពីណាខ្លះទៀតទៅ?

ឡោ ស្គាល់តែឈ្មោះទេណា...ហើយឃើញរូបថត ។

ឆាយ បាទ!

ឡោ តាម៉ុក,ខៀវ សំផន, អៀង សារី, ប៉ុល ពត ។

ឆាយ ៨...

ឡោ មេធំហើយណាស់..ហើយមេកំប៉ិកកំប៉ុក..ក្រោយយួនរំដោះបានហ្អាស់ ។

ឆាយ អូ..អាណឹងរឿងផ្សេងទេ មិនបាច់និយាយទេ...និយាយពី ៧៥ មៅទល់ ៧៩...

ឡោ បាទ!

ឆាយ ចុះពូយល់ថាអាកាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗណឹងវាអាចផ្តល់ផល ប្រយោជន៍អីដល់ពូ ដល់អ្នកស្រុកយើង ដល់ប្រទេសជាតិយើងដែរទេ?

ឡោ ខ្មែរក្រហមណឹងហ្អែស់...?

ឆាយ ដូចថាសព្វថ្ងៃណឹងអង្គការសហប្រជាជាតិ ហើយនិងរដ្ឋាភិបាលយើងរួមគ្នាបង្កើតតុលាការ មួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមណឹង ។ហើយខ្ញុំចង់សួរពូថាតើការគាត់ទោសណឹង វា បានផ្តល់អ្វីខ្លះដល់ពូ ហើយដល់ប្រទេសជាតិយើង ។

ឡោ ផ្តល់ដូចជាសម្តេចហ៊ុន សែន សព្វថ្ងៃនេះផ្តល់សាលារៀន ហើយ និងផ្លូវថ្នល់ ។

ឆាយ បាទ! ពូដែលស្គាល់ពាក្យថាយុត្តិធម៌ទេពូ យុត្តិធម៌គេសំដៅទៅន័យយ៉ាងម៉េដែរពូ?

ឡោ យុត្តិធម៌គឺសង្គ្រោះ...

ឆាយ បា!

ឡោ ត្រូវទេ?

ឆាយ បាទ!

ឡោ ទេកុំឲ្យបេះតែបាទណាស់...

ឆាយ ថាត្រូវតែទាំងអស់ណឹង ។ បើសិនមានការកាត់ទោសមេដឹកនាំខ្មែរក្រហមណឹងហ្អាស់ វា អាចផ្តល់យុត្តិធម៌" ឲ្យយើងខ្លះដែរឬអត់ទេ? ពូយល់ទេ..?

ឡោ ....?

ឆាយ ឥឡូវខ្ញុំសួរទៅមុខទៀត...បើពូអត់ដឹងរំលងចោលចុះ...ហីពូពេញចិត្តឲ្យមានតុលាការកាត់ ទោសមេដឹកនាំខ្មែរក្រហមណឹងដែរអត់?

ឡោ ខ្ញុំពេញចិត្ត ។

ឆាយ ព្រោះអី?

ឡោ ព្រោះរបបណឹងខ្ញុំអត់ពេញចិត្ត របបពុករលួយក៏ខ្ញុំអត់ចូលចិត្តដែរ ។

ឆាយ ហើចុះបើសិនជាគេកាត់ទោសពួកណឹងពូចង់ឲ្យគេកាត់ទោសដោយវិធីណា?
ជាប់គុកម៉ាជីវិត, ប្រហាជីវិត, ឬក៏ ១០,២០ ឆ្នាំ យកអាណាឥឡូវ?

ឡោ ខ្ញុំថាចង់ឲ្យកាត់ផ្តាច់កុំឲ្យមានខ្មែរក្រហម ។

ឆាយ និយាយថាមេធំៗណឹងហ្នាស៎ គេត្រូវយកម៉ៅប្រឈមមុខនឹងតុលាការ ដើម្បីឲ្យតុលាករ
កំណត់ទោស កំណត់ថាឥឡូវប៉ុន្មានឆ្នាំៗ ។
ចុះបើគំនិតរបស់ពូវិញចង់ឲ្យគេកាត់ទោសប៉ុន្មាន ឆ្នាំ
ដាក់គុកប៉ុន្មានឆ្នាំ? ឬក៏ប្រហាជីវិតអត់មានទេព្រោះស្រុកយើងឥឡូវមិនឲ្យមានទេ
ពូគិតថាម៉េច?

ឡោ ១០ឆ្នាំ ទៅ ២០ឆ្នាំ ។

ឆាយ ១០ឆ្នាំ ទៅ ២០ឆ្នា... ចុះបើគេចង់ដាក់ម៉ាជីវិហ្នឹងពូថាម៉េចឲ្យសមនិងទោសកំហុសរបស់
គាត់ពូថាម៉េច?

ឡោ តាមដំណើរ ។

ឆាយ បើអីចឹងអា ១០,២០ក៏បាន អាមួយជីវិតក៏បានដែរ ។

ឡោ អាណឹងសំណូមពរណឹងអីចឹង... ។

ឆាយ បាទ! អីចឹងពូចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមនែស៎...

ឡោ ខ្ញុំស្អប់ ។

ឆាយ ព្រោះស្អប់នឹងរបបណឹងហ្អែស៎?

ឡោ បាទ!

ឆាយ ព្រោះរបបណឹងវាធ្វើឲ្យពូយ៉ាំងម៉េចខ្លះ?

ឡោ ធ្វើឲ្យខ្ញុំមានស្នាមមានអីចេះ ធ្វើឲ្យពិបាកវេទនា ។

ឆាយ បាទ!អីចឹងពូមានយោបល់អីបន្ថែម
នូវអ៊ីដែលខ្ញុំមិនបានសួរពូហ្អាស៎? រឿងដែលពូដឹងហើយ ខ្ញុំអត់បានសួរហ្អាស៎?

ឡោ	បាទដែលខ្ញុំកំសត់កំរ៉ែមៅ៉ដែលបានលោកក្មួយដែលស្រាវជ្រាវអឺចេះសូមអរគុណ ដែលស្រាវជ្រាវពីបងខ្ញុំដែលស្លាប់ពីមូលហេតុអីចេះមួយៗពីរឿងខ្មែរក្រហម ។ខ្ញុំសូមអរគុណដល់ក្មួយហើយ ។

ឆាយ	អីចឹងខ្ញុំអត់មានអ៊ីសួរនាំពូទៀតទេ ខ្ញុំសួរពូដូចជាអស់អីសួរដែរហើយ អរគុណពូច្រើនណាស់ ដែលបានផ្តល់ពត៌មានអំពីរឿងរ៉ាវជីវិតរបស់លោកពូ ហើយនិងបងរបស់លោកពូណឹងហ្អាស៎ ឲ្យបានខ្ញុំដឹង ។ អីចឹងអរគុណពូច្រើនហើយណាស់ ។

ឡោ	បាទ!

–ចប់–